Unofficial Traslation

# Kingdom of Cambodia
# Nation Religion King

Sala Khet Oddar Meanchey
No. 755 ODM

27 July 2000

**3rd Deputy Governor of Oddar Meanchey Province**

through

**H.E Governor of Oddar Meanchey Province**

to

**Director of Phnom Penh Post**

Subject: Correction [to the article on Phnom Penh Post]

**Dear Director,**

I have read your newspaper article [Phnom Penh Post] on the "Road to Samrong preferred over Preah Vihear Route," by Annette Marcher and Vong Sokheng in relation to the road construction from Anlong Veng to Samrong, which was published in Volume 9, number 15 on July 15 - August 3, 2000.

I very much regret that when I met with Ms. Annette Marcher and Mr. Vong Sokheng, I had not yet received the information regarding the funding support of Government of Australia for road construction from Anlong Veng to Samrong. I would like to take this opportunity to make some corrections to the information [given to the Phnom Penh Post], as follows:

1 The Government of Australia through AUSAID has donated US$344,581 to support the SEILA program, a decentralized development program of the Royal Government of Cambodia, with support to capacity building, training and office space for the Provincial Rural Development Committee (PRDC). Within this budget, US$120,000 has been allocated for the road construction from Anlong Veng to Samrong. This is news has delighted the people of Oddar Meanchey province.

2 In relation to the 74 kilometer stretch that I mentioned, I want to have road rehabilitated all the way to the provincial center [Samrong town]. But if there is a shortage of budget, we would repair 54 kilometers from Anlong Veng to Champa Sok village of Koun Kriel commune, excluding the additional 20 kilometers from Champa Sosk to the provincial center.

Unofficial Traslation

According to the estimation made by the technician on the required budget, to complete this road including mine clearance and construction of bridges and culverts, we need more budget in addition to the funding from AUSAID. The provincial authorities have requested to the Royal Government for support of this high priority provincial road, in order to have effective communication between the province and Anlong Veng and Trapeang Prasat. At present, it is difficult to travel via Siem Reap province with a distance of more than 200 kilometers.

On behalf of the Governor and the people of Oddar Meanchey province, I would like to take this opportunity to express my deep gratitude to the Government and the People of Australia, who have provided support to our province through AUSAID. We would like to express our gratitude to CARERE organization that always pays attention and supports the development works in our young province.

I also take this opportunity to make an appeal to all national and international communities to please support the mine clearance activities so that the road construction work can begin soon.

Please publish my correction on next addition of your newspaper.

Mr. Director, please accept my honest respect.

Signature

3rd Deputy Governor
[Yim Thin]

Seen and agreed
Governor and as Chief of Provincial Rural Development Committee
[Signed and Seal]

**Copy for information:**
Cabinet of Prime Minister
H.E Co Minister of Interior
Australian Embassy in Kingdom of Cambodia
Provincial Program Manager, CARERE Banteay Meanchey

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាខេត្តឧត្តរមានជ័យ

លេខ ៧៥៥ ខ.ឧ ថ្ងៃទី ២៧ខែ កក្កដា ឆ្នាំ ២០០០

អភិបាលរងទី៣ខេត្តឧត្តរមានជ័យ

សូមគោរពជូនលោកនាយក សារពត៌មាន ភ្នំពេញប៉ុស្តិ៍

**តាមរយៈ** ឯកឧត្តមអភិបាលខេត្ត និងជាប្រធានគណកម្មាការអភិវឌ្ឍន៍ជនបទខេត្តឧត្តរមានជ័យ

**កម្មវត្ថុ** :សេចក្តីកែតំរូវ

លោកនាយកជាទីគោរពរាប់អាន !

ខ្ញុំបានអានរួចហើយនូវពត៌មានតាមកាសែតរបស់លោកនាយក ច្បាប់ទី ៩ លេខ ១៥ សំរាប់ពីថ្ងៃ១៥ កក្កដា ដល់ថ្ងៃ ៣សីហា ឆ្នាំ ២០០០ ដែលសរសេរ ដោយ លោកស្រី Anette Marcher និង លោក វង់ សុខេង លើ អត្ថបទដែលមានចំណងជើងថា “Road to Samrong is preferred over Preah Vihear Route” ដែល ទាក់ទិនទៅនឹងការ ធ្វើផ្លូវពីអន្លង់វែងទៅ សំរោង ។

ខ្ញុំមានការសោកស្តាយជាខ្លាំង ដែលក្នុងឱកាសខ្ញុំជួបជាមួយលោកស្រី Anette Marcher និង លោក វង់ សុខេង ខ្ញុំពុំទាន់បានទទួលពត៌មានដែលទាក់ទងនឹងជំនួយរបស់រដ្ឋាភិបាលអូស្ត្រាលី សំរាប់ធ្វើផ្លូវពីអន្លង់ វែងទៅ សំរោង ។ ខ្ញុំសូមយកឱកាសនេះ ធ្វើការតម្រូវពត៌មាននេះដូចតទៅ :

១. រដ្ឋាភិបាលអូស្ត្រាលី តាមរយៈ AUSAID បានផ្តល់ថវិកាចំនួន ៣៤៤.៥៨១ដុល្លា សំរាប់ចូលរួមគាំទ្រដល់កម្មវិធីសិលា ដែលជាកម្មវិធីអភិវឌ្ឍន៍វិមជ្ឈការរបស់រាជរដ្ឋាភិបាល ដោយមានការគាំទ្រកសាងសមត្ថភាព ហ្វឹកហ្វឺន និងផ្តល់ទីចាត់ការដល់គណកម្មាការអភិវឌ្ឍន៍ជនបទខេត្ត ។ ក្នុងនោះមានថវិកាចំនួន ១២០.០០០ដុល្លា នឹងត្រូវប្រើសំរាប់ ជាទុនធ្វើផ្លូវពី អន្លង់វែង ទៅសំរោង ។ នេះជាពត៌មានដ៏គួរអោយរីករាយសំរាប់ ប្រជាជនខេត្តយើងខ្ញុំ ។

២. ចំពោះចំងាយផ្លូវដែលខ្ញុំបានលើកឡើងថាមានប្រវែង ៧៤គម នោះគឺមានន័យថា ខ្ញុំចង់អោយមានការ ជួសជុលផ្លូវនេះរហូតដល់ទីរួមខេត្តតែម្តង ។ តែបើថវិកាមានមិនគ្រប់គ្រាន់ យើងអាចជួសជុលចំងាយ ផ្លូវប្រវែង ៥៤គម ពីអន្លង់វែងមកត្រឹមភូមិចំចាសុខ ឃុំកូនក្រៀលដោយមិនរាប់បញ្ចូលចំងាយផ្លូវ ២០គម ទៀត ពីចំចាសុខ ទៅទី រួមខេត្ត ។

តាមការប៉ាន់ប្រមាណរបស់អ្នកបច្ចេកទេសទៅលើតម្រូវការថវិកា ដើម្បីធ្វើផ្លូវនេះអោយបានសំរេចជាស្ថាពរនោះ ដោយគិតទាំងការដោះមីន និងរចនាសម្ព័ន្ធស្ពាន លូ ផងនោះ យើងត្រូវការថវិកាបន្ថែម ទៀតលើថវិកាដែលបានគាំទ្រដោយ AUSAID ហើយក្នុងនោះ អាជ្ញាធរខេត្ត បានលើកសំណើដល់ រដ្ឋា ភិបាល

អោយគាំទ្រលើការកសាងផ្លូវនេះជាអាទិភាពខ្ពស់របស់ខេត្ត ដើម្បីអោយមានប្រសិទ្ធិភាពដល់ការ ទំនាក់ ទំនង រដ្ឋបាល រវាងអាជ្ញាធរខេត្តជាមួយស្រុកអន្លង់វែង និងត្រពាំង ប្រាសាទ ដែលសព្វថ្ងៃនេះ កំពុងតែមានការលំបាកក្នុងការធ្វើដំណើរឆ្លងកាត់ខេត្តសៀមរាប ដែលមានចំងាយ ជាង ២០០គម ។

ក្នុងនាមអភិបាលខេត្ត និងក្នុងនាមប្រជាជនក្នុងខេត្តឧត្តរមានជ័យ ខ្ញុំសូមឆ្លៀតយកឱកាសនេះសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅដល់រដ្ឋាភិបាលនិងប្រជាជនអូស្រ្តាលី ដែលបានផ្តល់ការគាំទ្រដល់ខេត្តយើងខ្ញុំតាមរយៈ AUSAID និងសូមសំដែងនូវការដឹងគុណចំពោះអង្គការ ឃែរេរ ដែលតែងតែបានយកចិត្តទុកដាក់ជួយ ជ្រោមជ្រែងដល់កិច្ចអភិវឌ្ឍន៍ខេត្តដ៏ក្មេងខ្ចីរបស់យើងខ្ញុំ ។

ខ្ញុំក៏សូមឆ្លៀតយកឱកាសនេះ ធ្វើការអំពាវនាវដល់បណ្តាសហគមន៍ជាតិ អន្តរជាតិនានា សូមមេត្តាផ្តល់ការគាំទ្រដល់ការបោសសំអាតមីន ដើម្បីអោយដំណើរការធ្វើផ្លូវនេះបានឆាប់រហ័ស ។

សូមលោកនាយកមេត្តា ចុះផ្សាយការកែតំរូវរបស់ខ្ញុំនេះដោយអនុគ្រោះ ។

សូមលោកនាយកទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ ។

ហត្ថលេខា

អភិបាលរងទី ៣

បានឃើញនិងឯកភាព
អភិបាលខេត្ត និងជា ប្រធានគណកម្មាការអភិវឌ្ឍន៍ជនបទខេត្ត

ឌុប_សារិន

ចំលងជូន :
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ឯកឧត្តមសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
 ដើម្បីជូនជ្រាបជាពត៌មាន"
-ប្រធានអង្គការ ឃែរេរ ខេត្តបន្ទាយមានជ័យ
 ដើម្បីជូនជ្រាបជាពត៌មាន"
-ស្ថានឯកអគ្គរដ្ឋទូត អូស្រ្តាលី ប្រចាំរាជាណាចក្រកម្ពុជា